**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ :** ០៤១/១១ **ក.ប**/ស.ដ.ណ

រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែ មីនា ឆ្នាំ២០១១

# សេចក្តីជូនដំណឹង

គោរពតាមអនុសាសន៍ ជាគោលការណ៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹង ដល់អង្គការសហជីពគ្រប់ថ្នាក់ សមាគមនិយោជក កម្មករនិយោជិត និងនិយោជក នៃរោងចក្រ សហគ្រាស គ្រឹះស្ថាន ផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើង ទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា ឲ្យបានជ្រាបថា នៅថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១១ គណៈកម្មការប្រឹក្សាការងារ ដែលមានតំណាងមកពីខាងរាជរដ្ឋាភិបាល តំណាងមកពីខាងអង្គការសហជីព និងតំណាងមកពីខាងសមាគមនិយោជក បានធ្វើការប្រជុំពិភាក្សាគ្នា អំពីការផ្តល់អត្ថប្រយោជន៍ផ្សេងៗដូចជា ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ប្រាក់រង្វាន់ធ្វើការទៀងទាត់ និងប្រាក់រង្វាន់អតីតភាពការងារជូនកម្មករនិយោជិត ធ្វើការផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិត ស្បែកជើង ។

អង្គប្រជុំបានសម្រេចលទ្ធផលដូចខាងក្រោម ៖

១- កម្មករនិយោជិត ដែលបានមកធ្វើការទៀងទាត់តាមចំនួនថ្ងៃនៃថ្ងៃធ្វើការក្នុងខែនីមួយៗ ត្រូវទទួលបានប្រាក់រង្វាន់យ៉ាងតិចចំនួន ៧ (ប្រាំពីរ) ដុល្លារអាមេរិកក្នុងមួយខែ។

២- កម្មករនិយោជិត ដែលស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោង តាមសំណូមពររបស់និយោជក ត្រូវទទួលបានប្រាក់ថ្លៃបាយចំនួន ២០០០ (ពីរពាន់) រៀលក្នុងមួយថ្ងៃ ឬទទួលបានការផ្តល់ជូនបាយមួយពេលដោយឥតគិតថ្លៃ ។

៣- ប្រាក់រង្វាន់អតីតភាពការងារ

ក- កម្មករនិយោជិតដែលបានធ្វើការនៅក្នុងរោងចក្រ សហគ្រាស គ្រឹះស្ថានណាមួយលើសពីមួយឆ្នាំឡើងទៅ ត្រូវទទួលបានប្រាក់រង្វាន់អតីតភាពការងារ ដូចមាននៅក្នុងតារាងខាងក្រោមនេះ៖

| **អតីតភាពការងារ គិតជាឆ្នាំ** | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 |
|---|---|---|---|---|---|---|---|---|---|---|---|
| **ចំនួនទឹកប្រាក់ទទួលបានក្នុងមួយខែគិតជាដុល្លារអាមេរិក** | 0 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 |

៥- កម្មករនិយោជិតមានអតីតភាពការងារនៅឆ្នាំណា ត្រូវទទួលបានប្រាក់រង្វាន់អតីតភាពការងារក្នុងឆ្នាំនោះ (ដូចតារាងខាងលើ) លើកលែងតែកម្មករនិយោជិតដែលមានអតីតភាពការងារលើសពី ១១ ឆ្នាំ ឡើងទៅ ត្រូវទទួលបានប្រាក់រង្វាន់អតីតភាពការងារនៅក្នុងឆ្នាំទី ១១ គឺចំនួន ១១ (ដប់មួយ) ដុល្លារអាមេរិកក្នុងមួយខែ។

៤- ចំណុចទី ៤ នៃសេចក្តីជូនដំណឹងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លេខ ០៤៩/១០ បក/សជណ ចុះថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០១០ ត្រូវចាត់ទុកជានិរាករណ៍។

ការផ្តល់អត្ថប្រយោជន៍ផ្សេងៗ ដូចមានចែងក្នុងចំណុចទី ១, ទី ២ និងទី ៣ នៃសេចក្តីជូនដំណឹងនេះ ត្រូវអនុវត្តចាប់ពី**ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១១** តទៅ ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា កម្មករនិយោជិត អង្គការសហជីព សមាគមនិយោជក និងនិយោជកនៃរោងចក្រ សហគ្រាស គ្រឹះស្ថានផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើងទាំងអស់ នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះបានល្អប្រសើរ និងធានាបាននូវប្រសិទ្ធភាពខ្ពស់ ។

**រដ្ឋមន្ត្រី**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

វង្ស សុត

**<u>ចម្លងជូន:</u>**

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យលោកជំទាវ ឧបនាយករដ្ឋមន្ត្រី ប្រចាំការ
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ
"ដើម្បីជូនជ្រាប"
-គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត
-គ្រប់សមាគមនិយោជក
-គ្រប់សហព័ន្ធសហជីព
"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-រាជកិច្ច
-កាលប្បវត្តិ - ឯកសារ